# ច្បាប់ស្តីពីការបៀតបៀនផ្លូវភេទ

## សៀវភៅណែនាំសម្រាប់និយោជិតនៅក្នុងរដ្ឋវ៉ាស៊ីនតោន

## មនុស្សគ្រប់គ្នាគួរទទួលបានការប្រព្រឹត្តចំពោះខ្លួនដោយការគោរពនៅកន្លែងការងារ

**តើការបៀតបៀនផ្លូវភេទ ជាអ្វី?**

ការបៀតបៀនផ្លូវភេទ គឺជាទម្រង់នៃការរើសអើងផ្លូវភេទ មានដូចជាការប្រព្រឹត្តផ្លូវភេទដែលគេមិនពេញចិត្ត ការស្នើសុំផលតបស្នងផ្លូវភេទ និងការប្រព្រឹត្តលើរូបរាងកាយឬពាក្យសម្តីទៅលើផ្លូវភេទ។ ការបៀតបៀនផ្លូវភេទគឺជាការរំលោភបំពានចំពោះច្បាប់រដ្ឋ និងសហព័ន្ធ។

មានការបៀតបៀនផ្លូវភេទចំនួនពីរប្រភេទ៖

### 1 បរិយាកាសការងារមិនសមស្រប

ការបៀតបៀនដែលញឹកញាប់ ឬធ្ងន់ធ្ងររហូតរារាំងសមត្ថភាពរបស់អ្នកក្នុងការបំពេញការងារ។ អាកប្បកិរិយានេះត្រូវតែផ្តោតទៅលើអ្នក ដោយសារតែបញ្ហាយេនឌ័ររបស់អ្នក ហើយអាចរួមមានការបញ្ចេញយោបល់ ឬការលេងសើចទៅលើយេនឌ័រ ឬផ្លូវភេទដែលគេមិនពេញចិត្ត ការស្នើសុំច្រើនលើកច្រើនសារដែលគេមិនពេញចិត្តសម្រាប់ការណាត់ជួប កាយវិការបំពារបំពាន ការប៉ះពាល់ដោយមិនសមស្រប ឬការបង្ហាញឯកសាររូបភាពអាសអាភាស។

### 2 ការផ្លោះប្តូរ

ការបៀតបៀនដែលកើតមាននៅពេលប្រធាន ឬអ្នកគ្រប់គ្រងស្នើសុំផលតបស្នងផ្លូវភេទពីអ្នក ជាថ្នូរទៅនឹងអត្ថប្រយោជន៍ការងារដូចជាការដំឡើងតួនាទី ការដំឡើងប្រាក់ខែ ឱកាសអភិវឌ្ឍអាជីពការងារ គម្រោងពិសេស ឬអត្ថប្រយោជន៍ផ្សេងទៀតពាក់ព័ន្ធនឹងការងាររបស់អ្នក។

**លក្ខខណ្ឌតម្រូវសម្រាប់និយោជក**

និយោជកអាចនឹងត្រូវទទួលខុសត្រូវចំពោះការបៀតបៀនផ្លូវភេទ ប្រសិនបើពួកគេមិនអនុម័ត និងពង្រឹងការអនុវត្តគោលនយោបាយដើម្បី៖

- ផ្តល់នីតិវិធីសម្រាប់និយោជិតដែលបានជួបប្រទះបញ្ហាបៀតបៀនផ្លូវភេទដើម្បីធ្វើការរាយការណ៍ប្តឹងតវ៉ា
- ធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ និងជាបន្ទាន់ទៅលើការប្តឹងតវ៉ាលើការបៀតបៀនផ្លូវភេទ និង
- ចាត់វិធានការបន្ទាន់ និងមានប្រសិទ្ធភាពដើម្បីលុបបំបាត់ការបៀតបៀនផ្លូវភេទបន្តទៀតនៅក្នុងកន្លែងការងារ

**តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើខ្ញុំជួបប្រទះ ឬសង្កេតឃើញមានការបៀតបៀនផ្លូវភេទ?**

ប្រសិនបើអ្នកសង្កេតឃើញនិយោជិតកំពុងរងការបៀតបៀន ឬជួបប្រទះបញ្ហាបៀតបៀននេះដោយខ្លួនអ្នកផ្ទាល់ អ្នកគួរអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

(A) ទំនាក់ទំនងប្រាប់ដល់អ្នកប្រព្រឹត្តអំពើបៀតបៀន ឬប្រធានរបស់ពួកគេថា អាកប្បកិរិយាបំពាននោះមិនត្រូវបានស្វាគមន៍ទេ។

(B) រាយការណ៍ជាបន្ទាន់អំពីហេតុការណ៍នោះជូនដល់ថ្នាក់គ្រប់គ្រង ឬផ្នែកធនធានមនុស្ស។

(C) រាយការណ៍អំពីការបៀតបៀននេះទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាលទាំងនេះ៖

- Washington State Attorney General's Office (ការិយាល័យអគ្គរដ្ឋអាជ្ញារដ្ឋវ៉ាស៊ីនតោន) www.atg.wa.gov/have-civil-rights-complaint ឬទូរសព្ទទៅលេខ 1-800-551-4636
- Washington State Human Rights Commission (គណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋវ៉ាស៊ីនតោន), www.hum.wa.gov/discrimination-complaint
- U.S. Equal Employment Opportunity Commission (គណៈកម្មាធិការសម្រាប់ឱកាសការងារស្មើភាពគ្នារបស់សហរដ្ឋអាមេរិក), www.eeoc.gov/employees/charge.cfm

**Washington State Office of the Attorney General**
(360) 753-6200
www.atg.wa.gov

*ព័ត៌មាននេះ ត្រូវបានផ្តល់ជូនជាធនធានសម្រាប់ការអប់រំទូទៅ និងមិនផ្តល់ជូនសម្រាប់គោលបំណងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដោយប្រការណាមួយឡើយ។*